**មាត្រា ២៨.-** អនុក្រឹត្យនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

សម្តេចនាយករដ្ឋមន្ត្រី

| | |
|---|---|
| ជ. រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច |
| រដ្ឋលេខាធិការ | និងហិរញ្ញវត្ថុ |
| ហត្ថលេខា | ហត្ថលេខា |
| **ត្រាំ អ៊ីវតឹក** | **គាត ឈន់** |

★★★

# អនុក្រឹត្យលេខ ៥១ អនក្រ.បក

## ស្តីពីការបង្កើតកំពង់ផែស្វយ័តភ្នំពេញ ក.ស.ភ.

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៥៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឲ្យប្រើ ដោយព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន

www.pheakdeylaw.com

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្ដីពីការអនុវត្តព្រះរាជក្រមស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ

-តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន និង របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

## ជំពូក ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១.-** ត្រូវបានបង្កើតសហគ្រាសសាធារណៈដែលមានលក្ខណៈជាក្រុមហ៊ុនរដ្ឋមានឈ្មោះ "កំពង់ផែស្វយ័តក្រុងភ្នំពេញ" សរសេរកាត់ (ក.ស.ភ) ដែលស្ថិតក្រោមអាណាព្យាបាល ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

- ក.ស.ភ មានទីស្នាក់ការនៅក្រុងភ្នំពេញ
- ក.ស.ភ គឺជានីតិបុគ្គលមានស្វ័យភាពផ្នែកបច្ចេកទេសរដ្ឋបាលនិងហិរញ្ញវត្ថុ ។
- ក.ស.ភ ត្រូវស្ថិតក្រោមឥទ្ធិពលនៃបទបញ្ញត្តិនៃអនុក្រឹត្យនេះ ហើយនិងគោរពតាមបទបញ្ញត្តិនៃព្រះរាជក្រមលេខ ០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ព្រមទាំងបទបញ្ញត្តិនៃច្បាប់ពាណិជ្ជកម្ម ។

**មាត្រា ២ .-** ក.ស.ភ មានភារកិច្ចធ្វើអាជីវកម្ម-សេវាកម្មមួយចំនួនលើការងារ :

-កណ្ដោធារកិច្ច នាំនាវាចេញ-ចូល និងផ្ដល់សេវាការចតនាវា

-លើកដាក់ផ្ទេរ-ស្ដុកនិងដឹកជញ្ជូនទំនិញ

-ការងារថែរក្សា ស្ដុកទំនិញ ឃ្លាំង ទីលាន

-ការងារអភិវឌ្ឍន៍ និងស្ដារហេដ្ឋារចនាសម្ព័ន្ធ ក.ស.ភ ដែលមាន ដែលត្រូវពង្រីក

**មាត្រា ៣ .-** ក.ស.ភ មានភារកិច្ច :

-ទទួលខុសត្រូវ និងចាត់ចែងលើការងារការពារសុវត្ថិភាព សន្តិសុខ សណ្ដាប់ធ្នាប់ក្នុង តំបន់គ្រប់គ្រង ។

-ប្រកាន់គោលការណ៍ និងរបៀបកិច្ចការ ពាណិជ្ជនិងអាជីវករ ។

-គ្រប់គ្រងដឹកនាំ និងចាត់ចែងសកម្មភាព ឲ្យមានប្រសិទ្ធភាព និងមានការរីកចំរើន ។

-ក្នុងឋានៈជាស្ថាប័នសាធារណៈ ក.ស.ភ ទទួលពីរដ្ឋ នូវអំណាច និងកាតព្វកិច្ចទាំងឡាយ ដើម្បីបំពេញ បេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន ។

www.pheakdeylaw.com

មាត្រា ៤ .- លើកលែងតែមានបញ្ញត្តិផ្ទុយពីនេះ គ.ស.ត ត្រូវអនុលោមតាមការគ្រប់គ្រងតាមច្បាប់ និងបទបញ្ញា ជាធរមាន ។

មាត្រា ៥ .- ដើមទុនដំបូងនៃ គ.ស.ត ត្រូវកំណត់ដោយការផ្តល់មូលធនដំបូង ដែលបានមកពីការបែងចែកពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសាធារណការនិងដឹកជញ្ជូន ។

-ពេលដែលអនុក្រឹត្យនេះចូលជាធរមាន គ.ស.ត ត្រូវកាន់កាប់កម្មសិទ្ធិពេញច្បាប់ជំនួសរដ្ឋ លើទ្រព្យសម្បត្តិទាំងអស់ ដែលបានកត់ត្រាក្នុងបញ្ជីសារពើភ័ណ្ឌ ។

មាត្រា ៦ .- បុគ្គលិក គ.ស.ត ត្រូវស្ថិតក្រោមលក្ខន្តិកៈដោយឡែក ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ដោយផ្អែកលើព្រះរាជក្រម ស្តីពីលក្ខន្តិកៈមូលដ្ឋាននៃសហគ្រាសសាធារណៈ ។ រាប់ពីពេលដែលលក្ខន្តិកៈដោយឡែកនេះចូលជាធរមាន បុគ្គលិកទាំងអស់របស់ គ.ស.ត មិនស្ថិតក្នុង ក្របខ័ណ្ឌការរដ្ឋតទៅទៀតទេ ។

ជំពូក ២

ការដឹកនាំ និងការគ្រប់គ្រង

មាត្រា ៧ .- គ.ស.ត ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសិទ្ធិអំណាចទូលំទូលាយ ដើម្បីបំពេញមុខងារក្នុងក្របខ័ណ្ឌ នៃបញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

-ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| -តំណាងក្រសួងសាធារណការនិងដឹកជញ្ជូន | ១រូប | ជាប្រធាន |
| -តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១រូប | ជាសមាជិក |
| -តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១រូប | ជាសមាជិក |
| -តំណាងអាជ្ញាធរក្រុងព្រះសីហនុ | ១រូប | ជាសមាជិក |
| -តំណាងក្រសួងពាណិជ្ជកម្ម | ១រូប | ជាសមាជិក |
| -តំណាងនិយោជិតរបស់ គ.ស.ត | ១រូប | ជាសមាជិកស្វ័យប្រវត្តិ |
| -អគ្គនាយក គ.ស.ត | ១រូប | ជាសមាជិក |

មាត្រា ៨ .- សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រីសកម្ម ធ្លាប់បានបំពេញការងារយ៉ាងតិច ០៥ (ប្រាំឆ្នាំ) ឬជាឥស្សរជន ដែលមានអាយុមិនលើសពី ៦៥ឆ្នាំ និងមានបទពិសោធន៍ ការងារគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ក្នុងវិស័យសេដ្ឋកិច្ចវិទ្យាសាស្ត្រ ឬនីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និង ពុំដែលមានទោសទណ្ឌកម្ម ព្រហ្មទណ្ឌណាមួយ ពីតុលាការឡើយ ។

-សមាជិកក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យ [illegible] អាណត្តិ ៣ឆ្នាំ ។ អាណត្តិនេះ អាចបញ្ចប់បានគ្រប់ពេលវេលា និងអាចបន្តទៀតបាន [illegible] អនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរដែលខ្លួនតំណាងឲ្យ ។

-តំណាងនិយោជិត ត្រូវជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមនិយោជិត គ.ស.ត ។

www.pheakdeylaw.com

**មាត្រា ៩.-** ក្រុមប្រឹក្សាភិបាលមានសមត្ថកិច្ចនិងភារកិច្ច ដើម្បីសម្រេចលើគោលនយោបាយ ក.ស.ភ ព្រមទាំងត្រួតពិនិត្យ ការងារគ្រប់គ្រងទូទៅ និងការត្រួតពិនិត្យលើសកម្មភាពទាំងអស់ ជាអាទិ៍ ៖

១- ផ្តល់ការយល់ព្រមលើផែនការអភិវឌ្ឍន៍ ព្រមទាំងថវិកាប្រចាំឆ្នាំ ដែលអគ្គនាយកបានស្នើ ។

២- ពិនិត្យតារាងតុល្យការប្រចាំឆ្នាំ ព្រមទាំងពិនិត្យលទ្ធផលការងារ ដើម្បីកែសម្រួលឱ្យបានសមស្របតាមគោលការណ៍ ។

៣- ផ្តល់ការយល់ព្រមលើគម្រោងការវិនិយោគប្រចាំឆ្នាំ និង ការពារការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ ក.ស.ភ ។

៤- សម្រេចតាមសំណើរបស់អគ្គនាយក ស្តីពីការតែងតាំង និង បញ្ឈប់ពីតួនាទីមន្ត្រីជាន់ខ្ពស់ ព្រមទាំងអត្ថប្រយោជន៍និងប្រាក់បៀវត្សរ៍ប្រាក់ឧបត្ថម្ភផ្សេងៗ សម្រាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយជាធរមាន ។

៥- ផ្តល់ការយល់ព្រមលើកិច្ចសន្យា និងអនុសញ្ញាដែល ក.ស.ភ ជាភាគីត្រូវបោះពុម្ព ហ៊ុំហ៊ុន និង លិខិតបំណុលមានប្រយោជន៍ក្នុងរយៈពេលជាធរមាន ស្តីពីកិច្ចសន្យា និងអនុសញ្ញា ដែលចុះដោយ សមត្ថភាពក្នុងការនោះ ។

៦- សម្រេចបង្កើត លើក ឬរំលាយ ការិយាល័យ និងផ្លាស់ប្តូរទីតាំងរបស់ ក.ស.ភ តាមការ វិនិច្ឆ័យរបស់ខ្លួន ។

៧- កំណត់ថ្លៃសេវាពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម សេវាកម្ម លើកំពង់ផែ ។

**មាត្រា ១០.-** ក្រុមប្រឹក្សាភិបាលបើកអង្គប្រជុំគ្រប់ពេល អាស្រ័យលើតម្រូវការនៃការងារ តាមការ អញ្ជើញរបស់ប្រធាន ឬតាមសំណើនៃសមាជិកដែលមានចំនួនយ៉ាងតិចពាក់កណ្តាលនៃចំនួនសមាជិក ទាំងអស់ ។

យ៉ាងហោចណាស់ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំយ៉ាងតិច១ដង ក្នុងរយៈពេលបីខែ។ ករណីមានធុរៈ ត្រូវជ្រើសរើសសមាជិកម្នាក់ដែលមានវ័យចំណាស់ជាងគេ ដើម្បីដឹកនាំ ការប្រជុំ ។

ក្រុមប្រឹក្សាភិបាលត្រូវពិភាក្សាលើបញ្ហាទាំងឡាយ ដែលស្ថិតក្នុងក្របខ័ណ្ឌរបស់ខ្លួន ។ របៀបវារៈនៃការប្រជុំ ព្រមទាំងឯកសារពាក់ព័ន្ធទាំងឡាយ ត្រូវផ្ញើជូនសមាជិក ក្រុមប្រឹក្សាភិបាលគ្រប់រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋឱ្យបានយ៉ាងតិច ១០ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិកយ៉ាងតិច ពាក់កណ្តាល ។ បើសិនជាមិនគ្រប់កូរ៉ុមទេ ការប្រជុំត្រូវលើកទៅ ១៥ថ្ងៃ ក្រោយទៀត ដើម្បី ពិភាក្សាឡើងវិញ លើបញ្ហាតាមរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះ ពុំចាំបាច់ទាមទារ កូរ៉ុមទេ ។

www.pheakdeylaw.com

-សេចក្តីសំរេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការ អនុម័ត ដោយសំលេងភាគច្រើន នៃសមាជិកដែលមានវត្តមាន។ ក្នុងករណីជាការបែកសំលេងមានចំនួនស្មើគ្នា សំលេង របស់ប្រធាន ត្រូវចាត់ទុកជាសំលេងអាទិភាព ។

**មាត្រា ១១.-** សេចក្តីសំរេចនៃក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាទុកក្នុងសៀវភៅកំណត់ហេតុ ដែលត្រូវបានចុះ ហត្ថលេខាដោយប្រធាន លេខាធិការ និងសមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងផ្ញើច្បាប់ចម្លងទៅក្រសួងពាក់ព័ន្ធ ព្រមទាំងក្រសួង ពាក់ព័ន្ធ ដែលមានចែងក្នុងមាត្រា ២៩ នៃលក្ខន្តិកៈ ក្នុងរយៈ ១៥ថ្ងៃ គិតចាប់ពីថ្ងៃ ប្រជុំ។ ច្បាប់ចម្លងនៃសេចក្តីសំរេច ត្រូវមានហត្ថលេខារបស់ប្រធាន និងសមាជិកក្រុមប្រឹក្សា ភិបាលម្នាក់ដែលមានវត្តមានក្នុងកិច្ចប្រជុំនោះ ។

**មាត្រា ១២.-** អគ្គនាយកអាជ្ញាធរ ជាអ្នកគ្រប់គ្រងទូទៅនៃ ក.ស.ក និងត្រូវបានតែងតាំង សំរាប់អាណត្តិ ... ដោយព្រះរាជក្រឹត្យ តាមសំណើរបស់ក្រសួងអាណាព្យាបាល ។

**មាត្រា ១៣.-** ក្រុមប្រឹក្សាភិបាលត្រូវប្រគល់ឲ្យអគ្គនាយកនូវអំណាចចាំបាច់ សំរាប់ដំណើរការប្រចាំថ្ងៃ ដើម្បីមាន លទ្ធភាពគ្រប់គ្រាន់ សំរាប់ដឹកនាំសហគ្រាសត្រឹមត្រូវតាមច្បាប់ និងការណែនាំរបស់ក្រុមប្រឹក្សា- ភិបាល ។

ក្នុងក្របខ័ណ្ឌនេះអគ្គនាយកត្រូវ :

១- ស្នើគម្រោងការទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាល ពិនិត្យ និងអនុវត្តតាមសេចក្តី សំរេចរបស់ក្រុមប្រឹក្សាភិបាល ។ តាមពេលកំណត់ជាទៀងទាត់ អគ្គនាយកត្រូវរាយការណ៍ជូន ក្រុមប្រឹក្សាភិបាល អំពីសកម្មភាពរបស់ ក.ស.ក ។

២- គ្រប់គ្រង ក.ស.ក លើផ្នែករដ្ឋបាល បច្ចេកទេស អាជីវកម្ម និងហិរញ្ញវត្ថុ ។

៣- តំណាងឲ្យ ក.ស.ក ចំពោះមុខតុលាការទាំងឡាយ ក្នុងការចេញមុខជាដើមចោទ ស៊ើប អង្កេត ឬនីតិវិធីនានាក្នុងក្របខ័ណ្ឌច្បាប់ និងតាមសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៤- មានសិទ្ធិជ្រើសរើស តែងតាំង ដាក់ប្តូរតំណែង ឬបញ្ឈប់ការងារនិងមានសិទ្ធិបញ្ចូល ក្រុមការងារបច្ចេកទេស ឬមន្ត្រីគ្រប់រូប ដែលជាបុគ្គលិករបស់ ក.ស.ក ដោយអនុវត្តតាម (លក្ខន្តិកៈបុគ្គលិក) ឬច្បាប់ជាធរមាន និងតាមការសំរេចរបស់ក្រុមប្រឹក្សាភិបាល ។

៥- មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ ព្រមទាំងការផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រី ដែលនៅក្រោមឱវាទស្របតាមបទប្បញ្ញត្តិដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ។

តំណាងឲ្យ ក.ស.ក ចំពោះអាជ្ញាធរ និងតុលាការគ្រប់ជាន់ថ្នាក់ ក្នុងការលើកចោទ ប្រកាន់ពាក់ព័ន្ធការពារផលប្រយោជន៍ ក.ស.ក និងការរៀបចំផ្សេងៗ ។

**មាត្រា ១៤.-** បៀវត្សរបស់ក្រុមប្រឹក្សាភិបាល និង ប្រាក់បំណាច់របស់អគ្គនាយកនិងអគ្គនាយករង កំណត់ដោយក្រសួង អាណាព្យាបាល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៥.-** ការចុះនិងការអនុវត្តកិច្ចសន្យាដោយ ក.ស.ក ត្រូវគោរពតាមវិធាន និងនីតិវិធីដែលកំណត់ដោយ ច្បាប់ជាធរមាន ។

www.pheakdeylaw.com

## ជំពូក ៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៦.-** ក.ស.ភ កាន់កាប់គណនេយ្យរបស់ខ្លួនឲ្យបានត្រឹមត្រូវតាមបទបញ្ញត្តគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យដែលគេទទួលស្គាល់ជាទូទៅ ។

ការិយបរិច្ឆេទគណនេយ្យ ចាប់ផ្ដើមពីថ្ងៃ០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូនៃឆ្នាំដដែល ។

តុល្យការនិងគណនីគ្រប់គ្រងត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល មុនថ្ងៃទី៣០ ខែមីនា នៃឆ្នាំបន្ទាប់ឆ្នាំកិច្ចការិយបរិច្ឆេទ ដោយផ្អែកលើការពិនិត្យគណនេយ្យករជំនាញឯករាជ្យ មុនការជាស្នងការគណនី ។

តុល្យការនិងគណនីគ្រប់គ្រង ព្រមទាំងរបាយការណ៍របស់ស្នងការគណនី ត្រូវដាក់ជូនការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេលមិនលើសពី ១៥ថ្ងៃ រាប់ពីថ្ងៃដែលក្រុមប្រឹក្សាភិបាល បានពិនិត្យឯកសារទាំងឡាយ ។ ឯកសារទាំងនេះ ត្រូវបញ្ជូនទៅក្រសួង អាណាព្យាបាលផងដែរ ដើម្បីសុំមតិទៅតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា១៦ នៃច្បាប់ ស្ដីពីលក្ខន្តិកៈនៃសហគ្រាសសាធារណៈ ។

**មាត្រា ១៧.-** ស្នងការគណនី ត្រូវបានតែងតាំងដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសំរាប់ អាណត្តិបីការិយបរិច្ឆេទ ។ អាណត្តិនេះអាចបន្តទៀតបានតាមសំណើរបស់ក្រុមប្រឹក្សាភិបាល ។

-ប្រាក់បំណាច់សំរាប់ ស្នងការគណនី ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងត្រូវចំណាយក្នុងជំពូកបន្ទុកអាជីវកម្មរបស់ ក.ស.ភ ។

-ស្នងការគណនី ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់គណនីប្រចាំឆ្នាំ នៃការិយបរិច្ឆេទមានភាពស្មោះត្រង់ និងត្រឹមត្រូវល្អ ហើយឆ្លុះបញ្ចាំងអំពីភាពពិតប្រាកដនៃស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ភ ។

-បេសកកម្មរបស់ស្នងការគណនី អនុលោមតាមបទបញ្ញត្តិនៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី ២៦ ខែសីហា ឆ្នាំ ១៩៩៧ ស្ដីពីស្នងការគណនីនៃសហគ្រាសសាធារណៈ ។

-ស្នងការគណនីអាចចូលរួមប្រជុំជាមួយក្រុមប្រឹក្សាភិបាលបាន តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សាភិបាល ។

**មាត្រា ១៨.-** រៀងរាល់ឆ្នាំ មុនថ្ងៃ៣០ ខែកញ្ញា ក្រុមប្រឹក្សាភិបាល ត្រូវផ្ដល់ការយល់ព្រមពីគំរោង សហគ្រាសប្រចាំឆ្នាំ តាមសំណើរបស់អគ្គនាយក ហើយបញ្ជូនគំរោងនេះដើម្បីសុំការអនុម័តពីរដ្ឋមន្ត្រីក្រសួងអាណាព្យាបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**គំរោងប្រចាំឆ្នាំត្រូវបញ្ជាក់នូវ:**

១- កម្មវិធីវិនិយោគ ព្រមទាំងហិរញ្ញប្បទានសំរាប់សំរេចកម្មវិធីវិនិយោគនេះ ។

២- ថវិកាសំរាប់ដំណើរការនៃសហគ្រាស ។

៣-តម្លៃឈ្នួលលើកដាក់ប្រចាំ ដឹកជញ្ជូននិងតម្លៃឈ្នួលសេវានាវាចរណ៍-ពន្ធផែស្តុកបញ្ញើ ។

www.pheakdeylaw.com

៥- សេចក្តីណែនាំ និង ផែនការសំរាប់ភាគសំរេចនៃការសម្រួលវិនិយោគ។ កៃម៉ែនរចនាឌ។ អើរ ១៧១

៥- សេចក្តីណែនាំ និង ផែនការ សំរាប់ការសម្រេចលើគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ ក.ស.ក ។

មាត្រា ១៩.- ធនធាននៃ ក.ស.ក ជាអាទិ៍មាន :

-ប្រាក់ដើមទុនដែលរដ្ឋផ្តល់ឲ្យ (តុល្យការដំបូង នៅពេលបង្កើត) ប្រាក់ចំណូលផ្សេងៗ គ្រប់ប្រភេទ បានមកពីសកម្មភាពរបស់សហគ្រាស ។

-ប្រាក់បានមកពីការលក់ ឬការជួលចលនវត្ថុ និងអចលនវត្ថុរបស់ ក.ស.ក ។

-ប្រាក់ខ្ចីផ្សេងៗ និងប្រាក់អំណោយផ្សេងៗ ។

មាត្រា ២០.- ចំណាយនៃ ក.ស.ក រួមមាន :

-ចំណាយប្រព្រឹត្តិសំរាប់ដំណើរការ

-ចំណាយវិនិយោគ

-សងបំណុល

-ចំណាយផ្សេងៗ

មាត្រា ២១.- ក.ស.ក អាចមានគណនីចរន្តក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះ សំរាប់តម្រូវការរបស់ខ្លួន ។

មាត្រា ២២.- ជារៀងរាល់ឆ្នាំ ក្រោយពីការសំរេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រាក់ចំណេញ ដែល ក.ស.ក ទទួលបានក្រោយពីការទូទាត់ស្របតាមវិធានការគណនេយ្យ ដែលគេទទួលស្គាល់ ជាទូទៅ ត្រូវបញ្ចូលទៅក្នុងគណនីមូលនិធិបំរុងហិរញ្ញវត្ថុរបស់ ក.ស.ក ។

មាត្រា ២៣.- ការខ្ចីបុលរយៈពេលមធ្យម ឬ វែង សំរាប់ប្រើប្រាស់ក្នុងការវិនិយោគ ត្រូវមានការយល់ព្រមពី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន ។

## ជំពូក ៤

## ការទំនាក់ទំនងជាមួយរដ្ឋ

មាត្រា ២៤.- រយៈពេល១៥ ថ្ងៃ យ៉ាងយូរបំផុត ក្រោយពីការអនុម័តរបស់ក្រុមប្រឹក្សាភិបាល ក.ស.ក ត្រូវផ្ញើជូន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអាណាព្យាបាល និងរដ្ឋមន្ត្រីសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នូវឯកសារដូចខាងក្រោមនេះ ។

-កំណត់ហេតុប្រជុំនៃក្រុមប្រឹក្សាភិបាល

-គំរោងសហគ្រាស (ដូចមានចែងក្នុងមាត្រា ១៨) របាយការណ៍ស្តីពីសកម្មភាព-តុល្យការ និង គណនីគ្រប់គ្រងទាំងឡាយរបស់ ក.ស.ក

-របាយការណ៍របស់ស្នងការគណនី ។

www.pheakdeylaw.com

**មាត្រា ២៥.-** ត្រូវបានដាក់ឲ្យនៅអម ក.ស.ក. នូវមន្ត្រីត្រួតពិនិត្យម្នាក់ ដែលត្រូវតែងតាំងដោយប្រកាស តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរូបនេះ មានសិទ្ធិចូលរួម គ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈ តែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យត្រូវបំពេញបេសកកម្ម ដោយអនុលោម តាមបទប្បញ្ញត្តិនៃមាត្រាទី២០ ទៅ ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

**មាត្រា ២៦ .-** ក.ស.ក មានសិទ្ធិផ្អាកការងារ ចំពោះអតិថិជន ឬអ្នកជាប់ពាក់ព័ន្ធ ដែលពុំព្រមបង់ប្រាក់ថ្លៃឈ្នួលផ្សេងៗ តាមកិច្ចសន្យា និងកិច្ចព្រមព្រៀង ។

## ជំពូក ៥

## អវសានប្បញ្ញត្តិ

**មាត្រា ២៧.-** រាល់បទប្បញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។ ស្តេចរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រតិភូរាជរដ្ឋាភិបាលអភិបាលក្រុងភ្នំពេញ អគ្គនាយកកំពង់ផែ ស្វយ័តក្រុង ភ្នំពេញ ត្រូវអនុវត្ត នូវអនុក្រឹត្យនេះ ។

**មាត្រា ២៨ .-** អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

អ៊ឹង ហួត ហ៊ុន សែន

បានយកជូនឯកឧត្តមនាយករដ្ឋមន្ត្រីទី១ សម្តេចនាយករដ្ឋមន្ត្រីទី២

ជ.រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

រដ្ឋលេខាធិការ

ហត្ថលេខា

ត្រាំ អ៊ីវតឹក

ទេសរដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច

និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

★★★